# នៅពេលអ្នកទាក់ទងមក

## ខ្សែទូរសព្ទបន្ទាន់អាចជួយអ្នកបាន៖

- យល់ដឹងអំពីភាពខុសគ្នារវាងឧក្រិដ្ឋកម្មស្អប់ខ្ពើម និងហេតុការណ៍លម្អៀង
- ស្វែងយល់ថាមានជម្រើស និងធនធានអ្វីខ្លះ
- ភ្ជាប់ជាមួយសេវាកម្មដែលផ្តោតសំខាន់លើជនរងគ្រោះ ចេះដឹងអំពីវប្បធម៌ និងយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្តនៅក្នុងតំបន់របស់អ្នក

អ្នកអាចទាក់ទងទៅខ្សែទូរសព្ទបន្ទាន់បាន មិនថាអ្នកបានរងទង្វើនោះដោយផ្ទាល់ ឬបានឃើញនោះទេ។

# អំពី Hate Crimes & Bias Incidents Hotline

**ខ្សែទូរសព្ទបន្ទាន់គឺជាកន្លែងផ្តល់ព័ត៌មានមិនមែនអាសន្ន និងណែនាំបន្ត** ដើម្បីជួយបុគ្គលដែលរងការប៉ះពាល់ពីឧក្រិដ្ឋកម្មស្អប់ខ្ពើម និងហេតុការណ៍លម្អៀងឱ្យទទួលបានជំនួយ។ ខ្សែទូរសព្ទបន្ទាន់មានជាភាសាច្រើន និងរក្សាការសម្ងាត់។ ខ្សែទូរសព្ទបន្ទាន់ទាក់ទងទៅអាជ្ញាធរអនុវត្តន៍ច្បាប់ តែនៅពេលដែលអ្នកចង់ឱ្យទាក់ទង និងមានការយល់ព្រមពីអ្នកប៉ុណ្ណោះ។

## របៀបរាយការណ៍

855-225-1010

atg.wa.gov/report-hate

អ្នកនឹងត្រូវបានភ្ជាប់ទៅមនុស្សដែលនិយាយភាសារបស់អ្នក។

ខ្សែទូរសព្ទបន្ទាន់រក្សាការសម្ងាត់ ឥតគិតថ្លៃ និងមានផ្តល់ជូនទូទាំងប្រទេស ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក។ យើងមិនមែនជាប៉ូលិសទេ ហើយយើងក៏មិនរាយការណ៍ទៅប៉ូលិសដោយគ្មានការអនុញ្ញាតពីអ្នកដែរ។

ផ្តល់ជូនដោយ Washington State Office of the Attorney General (ការិយាល័យអគ្គរដ្ឋអាជ្ញានៃរដ្ឋវ៉ាស៊ីនតោន)។

Washington State Hate Crimes & Bias Incidents Hotline

រាយការណ៍អំពីការស្អប់ខ្ពើម ទទួលបានជំនួយ

# រាយការណ៍អំពីការស្អប់ខ្ពើម ទទួលបានជំនួយ

ការស្អប់ និងការលម្អៀងបង្កផលប៉ះពាល់ខ្លាំងលើបុគ្គល គ្រួសារ និងសហគមន៍។ Washington State Hate Crimes & Bias Incidents Hotline (ខ្សែទូរសព្ទបន្ទាន់សម្រាប់ឧក្រិដ្ឋកម្មស្អប់ខ្ពើម និងហេតុការណ៍លម្អៀងនៃរដ្ឋវ៉ាស៊ីនតោន) នៅទីនេះដើម្បីជួយដល់បុគ្គលដែលបានរង ឬបានឃើញទង្វើស្អប់ខ្ពើម។

ខ្សែទូរសព្ទបន្ទាន់ផ្តល់ជំនួយទូទាំងរដ្ឋ**ដោយឥតគិតថ្លៃ និងរក្សាការសម្ងាត់**។ អ្នកមិនចាំបាច់ដឹងថាតើអ្វីដែលបានកើតឡើងគឺជាឧក្រិដ្ឋឬអត់នោះទេ។ យើងនឹងជួយអ្នកឱ្យយល់ដឹងអំពីជម្រើសរបស់អ្នក។

## ទាក់ទងទៅខ្សែទូរសព្ទបន្ទាន់

855-225-1010

atg.wa.gov/report-hate

មានច្រើនភាសា

ខ្សែទូរសព្ទបន្ទាន់រក្សាការសម្ងាត់ ឥតគិតថ្លៃ និងមានផ្តល់ជូនទូទាំងប្រទេស ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក។ យើងមិនមែនជាប៉ូលិសទេ ហើយយើងក៏មិនរាយការណ៍ទៅប៉ូលិសដោយគ្មានការអនុញ្ញាតពីអ្នកដែរ។

ផ្តល់ជូនដោយ Washington State Office of the Attorney General។

**រាយការណ៍អំពីការស្អប់ខ្ពើម ទទួលបានជំនួយ**

## តើអ្វីជាឧក្រិដ្ឋកម្មស្អប់ខ្ពើម?

នៅរដ្ឋវ៉ាស៊ីនតោន ឧក្រិដ្ឋកម្មស្អប់ខ្ពើមអាចជារឿងមួយក្នុងចំណោមរឿងជាច្រើន។ វាអាចជា**ការបៀតបៀនលក្ខណៈព្យាបាទនិងដោយចេតនា ការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ឬការគំរាមបៀតបៀនឬគំរាមធ្វើឱ្យខូចទ្រព្យសម្បត្តិ**ទៅលើនរណាម្នាក់។

### ឧក្រិដ្ឋកម្មស្អប់ខ្ពើមត្រូវបានប្រព្រឹត្ត ដោយសារចំណុចដែលយល់ឃើញ ឬពិតជាក់ស្តែងដូចខាងក្រោមរបស់បុគ្គលនោះ៖

- ពូជសាសន៍
- ពណ៌សម្បុរ
- សាសនា
- ពូជពង្ស
- ជាតិកំណើត
- ភេទ
- ទំនោរផ្លូវភេទ
- អត្តសញ្ញាណ ឬការបង្ហាញអំពីភេទ
- ពិការភាពផ្លូវចិត្ត ផ្លូវកាយ ឬសតិបញ្ញា

**ឧក្រិដ្ឋកម្មស្អប់ខ្ពើមគឺជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅរដ្ឋវ៉ាស៊ីនតោន** (Revised Code of Washington (RCW, ក្រមដែលបានកែប្រែនៃរដ្ឋវ៉ាស៊ីនតោន) 9A.36.080)។

## តើអ្វីជាហេតុការណ៍លម្អៀង?

ហេតុការណ៍លម្អៀងគឺជា**ការបង្ហាញអរិភាពដោយការស្អប់គុំកួន**ចំពោះអ្នកដទៃដោយផ្អែកលើចំណុចដែលយល់ឃើញ ឬពិតជាក់ស្តែងដូចខាងក្រោមរបស់បុគ្គលនោះ៖

- ពូជសាសន៍
- ពណ៌សម្បុរ
- លទ្ធិ ឬសាសនា
- ពូជពង្ស
- ជាតិកំណើត
- ស្ថានភាពអន្តោប្រវេសន៍ ឬសញ្ជាតិ
- ភេទ
- ស្ថានភាពយោធា ឬអតីតយុទ្ធជនដែលរំសាយដោយកិត្តិយស
- ទំនោរផ្លូវភេទ
- អត្តសញ្ញាណ ឬការបង្ហាញអំពីភេទ
- ពិការភាពសតិបញ្ញា ផ្លូវចិត្ត ឬផ្លូវកាយ
- ការប្រើសុនខនាំផ្លូវដែលបានបង្ហាត់ ឬសត្វនាំផ្លូវ

### ហេតុការណ៍លម្អៀងមិនធ្ងន់ធ្ងរដល់កម្រិតឧក្រិដ្ឋកម្មទេ។

**ឧទាហរណ៍រួមមាន៖**

- ការប្រើភាសាប្រមាថដោយផ្អែកលើលក្ខណៈដែលយល់ឃើញ។
- ការបង្កើតរូបភាព ឬគំនូរអ្នករើសអើងជាតិសាសន៍ ឬប្រមាថ។
- ការចំអកពិការភាព ការអនុវត្តឬបទដ្ឋានវប្បធម៌របស់នរណាម្នាក់។